**ប្រការ ៥ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងឯកឧត្ដម អស់លោក ជាគណៈកម្មការ ដូចប្រការ ១ ត្រូវអនុវត្តសេចក្ដីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

===

រាជធានីភ្នំពេញ . ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០១

**សេចក្ដីសំរេចលេខ ៣៦**

**ស្ដីពីការបង្កើតគណៈកម្មការត្រួតពិនិត្យ និងស្រាវជ្រាវករណីមិនប្រក្រតី ដែលពាក់ព័ន្ធទៅនឹងការអនុវត្តន៍ការងារជំរឿនមន្ត្រីរាជការ ជាពិសេសការអនុវត្តន៍តារាងទូទាត់បៀវត្សតាមប្រព័ន្ធពត៌មានវិទ្យា នៅក្រសួងសុខាភិបាល**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់ និង ជាបន្ទាប់របស់រាជរដ្ឋាភិបាល

**សំរេច**

ប្រការ ១ : បង្កើតគណៈកម្មការត្រួតពិនិត្យ និងស្រាវជ្រាវករណីមិនប្រក្រតី ដែលពាក់ព័ន្ធទៅនឹងការអនុវត្តន៍ការងារជំរឿនមន្ត្រីរាជការ ជាពិសេសការអនុវត្តន៍តារាងទូទាត់បៀវត្សតាមប្រព័ន្ធពត៌មានវិទ្យា នៅក្រសួងសុខាភិបាល ដែលមានសមាសភាពដូចខាងក្រោម :

www.pheakdeylaw.com

១-ឯកឧត្តម **យឹន ចន** អគ្គលេខាធិការរង នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ប្រធាន

២-លោក **ហង្ស នាំឆាន** ប្រធានក្រុមគំរោងតារាងទូទាត់បៀវត្ស អនុប្រធាន

៣-លោក **ជុំភ មុន្នី** តំណាងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សមាជិក

៤-លោក **ទី ចំរើន** តំណាងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច សមាជិក

៥-លោកស្រី **ឈាង ច័ន្ទតារា** តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៦-លោកវរសេនីយ៍ឯក **អ៊ឹន មុនី** តំណាងអគ្គនាយកដ្ឋាននគរបាលជាតិ សមាជិក

៧-លោកវរសេនីយ៍ត្រី **គង្គ ឈឿន** តំណាងអគ្គបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

៨-លោក **កែវ ធីឡុង** តំណាងលេខាធិការដ្ឋាន នៃអង្គភាពប្រឆាំងនឹងអំពើពុករលួយ សមាជិក

៩-លោក **គល់ សារមេត** មន្ត្រីលេខាធិការដ្ឋាន នៃអង្គភាពប្រឆាំងនឹងអំពើពុករលួយ លេខាកត់ត្រា

**ប្រការ ២ :**

គណៈកម្មការនេះ មានភារកិច្ច :

-ចុះត្រួតពិនិត្យ និងស្រាវជ្រាវករណីមិនប្រក្រតី ដែលពាក់ព័ន្ធទៅនឹងសកម្មភាពអនុវត្តការងារជំរឿនមន្ត្រីរាជការ ជាពិសេសការអនុវត្តន៍តារាងទូទាត់បៀវត្សតាមប្រព័ន្ធពត៌មានវិទ្យា នៅក្រសួងសុខាភិបាល ។

-ធ្វើរបាយការណ៍ ស្តីពីលទ្ធផលនៃការត្រួតពិនិត្យករណីខាងលើនេះ ជូនរាជរដ្ឋាភិបាល ។

**ប្រការ ៣ :** សមាជិកគណៈកម្មការទាំងអស់ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៤ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អគ្គបញ្ជាការនៃអគ្គបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃ

www.pheakdeylaw.com

ប្រទេស និងសមាសភាពដែលមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតនេះទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

===

## III. ការិយាល័យក្រសួង

## I. ទីស្តីការរដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

## ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០១

**ប្រកាសលេខ ១៥៥ បន.ប្រក**

**ស្តីអំពីការរៀបចំ និងការគ្រប់គ្រង**

**ប្រព័ន្ធ និងសេវាកម្ម អ៊ីនធឺណែត ( Internet ) និងប្រភេទសេវា VoIP**

**នៅព្រះរាជាណាចក្រកម្ពុជា**

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

www.pheakdeylaw.com